ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

ទីស្តីការគណៈរដ្ឋមន្ត្រី

Council of Ministers

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

National Committee for Disaster Management

លេខ (No) ៤១ ស.ប.ក/គ.ជ.គ.ម.

រាជធានីភ្នំពេញ. ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩

*Phnom Penh.*

## លិខិតបង្គាប់ការ

## គណៈកម្មាការធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកែតម្រូវ មាត្រា១ និង មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២ ស្តីអំពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញប្រកាសលេខ ៣២ ប្រ.ក.គ.ជ.គ.ម ស្តីអំពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងស្មារតីអង្គប្រជុំថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០០៩ របស់ថ្នាក់ដឹកនាំគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការងារចាំបាច់ដើម្បីសម្របសម្រួលឆ្លើយតប និង ស្តារឡើងវិញក្រោយព្យុះកេតសាណា

## សម្រេច

<u>**ប្រការ១**</u>: បង្កើតក្រុមការងារព័ត៌មាន និង ទំនាក់ទំនង ដើម្បីដឹកនាំ និង សម្របសម្រួលការងារប្រមូលព័ត៌មាន និង ទិន្នន័យក្នុងការឆ្លើយតប និង ស្តារឡើងវិញក្រោយគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. | ឯកឧត្តម **រស់ សុវណ្ណ** អគ្គលេខាធិការរងទទួលបន្ទុកព័ត៌មាន និង ទំនាក់ទំនង | ប្រធាន |
| ២. | ឯកឧត្តម **ឡាំ ហេងហួត** ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | លោក **ជួប ស៊ីថន** ប្រធាននាយកដ្ឋានឆ្លើយតប និង ស្តារឡើងវិញ | សមាជិក |
| ៤. | លោក **ម៉ា នរិទ្ធិ** ប្រធាននាយកដ្ឋានព័ត៌មាន និង ទំនាក់ទំនង | សមាជិក |
| ៥. | លោក **ម៉ី ធិរត្ន** អនុប្រធានមជ្ឈមណ្ឌលសម្របសម្រួលកិច្ចការគ្រោះអាសន្ន | សមាជិក |

**ប្រការ២**: ក្រុមការងារមានភារកិច្ចសម្របសម្រួល និង ធ្វើទំនាក់ទំនងជាមួយក្រសួង-ស្ថាប័ន និង ដៃគូនានាក្នុងការប្រមូល និង ទិន្នន័យ ធ្វើការប៉ាន់ប្រមាណការខូចខាត និង តម្រូវការ ដើម្បីឆ្លើយតប និង ស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។

**ប្រការ៣**: អគ្គលេខាធិការ អគ្គលេខាធិការរង នាយកខុទ្ទកាល័យ មន្ត្រី-បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

**កន្លែងទទួល** :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាយាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ក្រសួង-ស្ថាប័នសមាជិក និងដៃគូ គ.ជ.គ.ម

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

**ញឹម~វណ្ណដា**